February 28, 2019

# សមាជិកសភាអាមេរិក ស្នើច្បាប់ដក ឬ ព្យួរប្រព័ន្ធអនុគ្រោះពន្ធទូទៅ ឬ GSP



សមាជិកសភា ពីខាងគណបក្សប្រជាធិបតេយ្យលោក អាឡែន ឡូវ៉ែនស្សល (Alan Lowenthal) (រូបឆ្វេង) និង លោក ស្ទីវ ឆាបុត្រ (Steve Chabot) ពីខាងគណបក្សសាធារណៈរដ្ឋ (រូបស្តាំ)។ Courtesy of the Congressmen Facebook Profiles

មួង ណាវ៉េត RFA 2019-02-26

សមាជិកសភាអាមេរិកទាំងពីរគណបក្ស បានស្នើច្បាប់ដក ឬ ព្យួរប្រព័ន្ធអនុគ្រោះពន្ធទូទៅ (ឬ GSP)។

សមាជិកសភាមកពីខាងគណបក្សប្រជាធិបតេយ្យលោក អាឡែន ឡូវ៉ិនស្សល (Alan Lowenthal) និង លោក ស្ទីវ ឆាបុត្រ (Steve Chabot) ពីខាងគណបក្សសាធារណៈរដ្ឋ កាលពីជាងពីម៉ោង មុនការផ្សាយនេះ បានស្នើច្បាប់ស្តីពីពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០១៩ ដើម្បីឲ្យរដ្ឋាភិបាលអាមេរិក ពិចារណាឡើងវិញ លើប្រព័ន្ធអនុគ្រោះពន្ធទូទៅផ្នែកពាណិជ្ជកម្មនេះ ដោយសារតែ របបលោក លោក ហ៊ុន សែន រំលោភសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យធ្ងន់ធ្ងរ។

លោក អាឡែន ឡូវិនសូល បញ្ជាក់ថា "របបលោក ហ៊ុន សែន បំផ្លាញពន្ធកត្រួយប្រជាធិបតេយ្យ ដែលកំពុងដុះនៅអាស៊ីអាគ្នេយ៍"។ លោកបន្តថា "លោក ហ៊ុន សែន រម្លាយឆន្ទៈរបស់ពលរដ្ឋខ្មែរ ដោយបំផ្លាញការសន្យា ក្នុងការរៀបចំឲ្យមានការបោះឆ្នោត ដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ និង បន្តដណ្តើមក្រាញអំណាច ដោយរបៀបផ្តាច់ការ"។ លោកបន្ថែមថា "របបនេះ ប្រើប្រាស់ការគម្រាមកំហែង សម្លុតបំភ័យ អំពើហិង្សា និង ការសម្លាប់មនុស្សផង ធ្វើជាឧបករណ៍ក្នុងការបន្តក្រាញអំណាចនេះ។ ដូច្នេះ ទាំងលោក ហ៊ុន សែន និង របបនេះ ត្រូវតែទទួលទណ្ឌកម្ម ចំពោះអំពើដែលខ្លួនបានសាង"។

ក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP នេះ កម្ពុជានាំចេញទំនិញទៅសហរដ្ឋអាមេរិក ដោយឥតបង់ពន្ធ គិតជាទឹកប្រាក់ជាង ១៨០ លានដុល្លារ ក្នុងមួយឆ្នាំៗ។ សហរដ្ឋអាមេរិក បានបន្តផ្តល់ប្រព័ន្ធអនុគ្រោះពន្ធទូទៅនេះ ទៅកម្ពុជា កាលពីខែ មេសា ឆ្នាំ ២០១៨។

សមាជិកព្រឹទ្ធសភាអាមេរិក លោក ថិត គ្រូស (TED Cruz) និង លោក គ្រីស ឃូនស៍ (Chris Coons) ឯណោះ កាលពីថ្ងៃទី៩ ខែមករា ក៏បានដាក់សេចក្តីស្នើច្បាប់ស្តីពីពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៩នេះដែរ។

ការពិចារណាឡើងវិញនៃការអនុគ្រោះពន្ធនេះ រួមមាន ការដកទាំងស្រុង ព្យួរ ឬកាត់បន្ថយការផ្តល់ការអនុគ្រោះពន្ធ ដែលផ្តល់ដល់កម្ពុជា៕